**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ០២១០ រ៉ែ.ថម.ប្រក

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

# ប្រកាស
# ស្តីពី
# បទប្បញ្ញត្តិបច្ចេកទេសក្នុងការគ្រប់គ្រងដំណើរការកត់ត្រាទិន្នន័យស្លរ៉ែមាស ក្នុងបន្ទប់ស្លរ៉ែមាស

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៩ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណស្វែងរុករក និងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១ ) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥ ) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥ ) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ ០៣២០ រថ.អធរ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះឱ្យនាយកដ្ឋាននានានៃអគ្គនាយកដ្ឋានធនធានរ៉ែ
- បានឃើញប្រកាសលេខ ០៣០៨ រថ.អរ.ប្រក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ ស្តីពីវិធាននៃអធិការកិច្ចធនធានរ៉ែសម្រាប់ប្រតិបត្តិការធនធានរ៉ែក្រោមអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ អាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម អាជ្ញាបណ្ណស្វែងរុករករ៉ែ និងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល

## សម្រេច

### ប្រការ១.. គោលបំណង

ប្រកាសនេះ មានគោលបំណងបង្កើនប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព ក្នុងប្រតិបត្តិការអាជីវកម្មរ៉ែមាស ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ និងបទប្បញ្ញត្តិពាក់ព័ន្ធនានាជាធរមាន ដោយកំណត់យន្តការទទួលខុសត្រូវ គោលការណ៍អនុវត្ត តួនាទីរបស់មន្ត្រីមានសមត្ថកិច្ចរ៉ែ និងថាមពល និងសម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ក្នុងដំណើរការស្លរ៉ែមាស។

### ប្រការ២.. វិសាលភាព

ប្រកាសនេះ មានវិសាលភាពអនុវត្តសម្រាប់ការគ្រប់គ្រងដំណើរការកត់ត្រាទិន្នន័យស្លរ៉ែមាសក្នុងបន្ទប់ស្លរ៉ែមាស របស់សម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ (សម្រាប់អាជីវកម្មរ៉ែមាស) នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ប្រការ៣.. និយមន័យ

មន្ត្រីមានសមត្ថកិច្ច សំដៅដល់មន្ត្រីដែលត្រូវបានចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល ក្នុងការបំពេញភារកិច្ចកត់ត្រាទិន្នន័យស្លរ៉ែមាសក្នុងបន្ទប់ស្លរ៉ែមាស។

សម្បទានិកដែលមានអាជ្ញាបណ្ណ សំដៅដល់សម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ(សម្រាប់អាជីវកម្មរ៉ែមាស)។

ការស្លរ៉ែមាស សំដៅដល់ដំណើរការស្លកំហាប់រ៉ែមាស(Gold Concentrates) ទៅជាដុំមាស (Gold Doré)។

### ប្រការ៤.. ការចាត់តាំងមន្ត្រីមានសមត្ថកិច្ច

ក្រសួងរ៉ែ និងថាមពលត្រូវចាត់តាំងឱ្យមានក្រុមការងារមន្ត្រីមានសមត្ថកិច្ច ដើម្បីគ្រប់គ្រងដំណើរការកត់ត្រាទិន្នន័យស្លរ៉ែមាសក្នុងបន្ទប់ស្លរ៉ែមាស។ សមាសភាពក្រុមការងារមន្ត្រីមានសមត្ថកិច្ច ត្រូវរៀបចំជាបញ្ជី



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១ ) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥ ) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥ ) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ដោយមានអត្តសញ្ញាណសម្គាល់ដែលមានបិទរូបថត ហើយត្រូវផ្ញើជូនសម្បទានិកដែលមានអាជ្ញាបណ្ណ យ៉ាងតិច ០៥ (ប្រាំ) ថ្ងៃ មុននឹងបេសកកម្មត្រូវបានរៀបចំឡើង ។

ក្រុមការងារមន្ត្រីមានសមត្ថកិច្ច ត្រូវដឹកនាំដោយប្រធានមួយរូប និងសមាជិកមួយចំនួនតាមការចាំបាច់។

## ប្រការ៥.. នីតិវិធីនៃការជូនដំណឹងនៃដំណើរការស្លរ៉ែមាស

ក្នុងរយៈពេលយ៉ាងតិច ១៥(ដប់ប្រាំ)ថ្ងៃ មុនចាប់ផ្តើមត្រីមាសនីមួយៗ សម្បទានិកដែលមានអាជ្ញាបណ្ណ ត្រូវផ្តល់ជូនមកក្រសួងរ៉ែ និងថាមពល នូវផែនការកាលវិភាគស្លរ៉ែមាសសម្រាប់មួយត្រីមាស ឬតាមការតម្រូវរបស់ក្រសួងរ៉ែ និងថាមពល។

សម្បទានិកដែលមានអាជ្ញាបណ្ណ ត្រូវជូនដំណឹងមកប្រធានក្រុមការងារមន្ត្រីមានសមត្ថកិច្ច ឱ្យបានយ៉ាងតិចមុន ៤៨ (សែសិបប្រាំបី) ម៉ោង នៃសប្តាហ៍នីមួយៗ អំពីកាលបរិច្ឆេទជាក់លាក់នៃដំណើរការស្លរ៉ែមាស ក្នុងសប្តាហ៍នោះ។ រាល់ការកែប្រែកាលបរិច្ឆេទស្លរ៉ែមាសណាមួយក្នុងសប្តាហ៍ សម្បទានិកដែលមានអាជ្ញាបណ្ណ ត្រូវជូនដំណឹងមកប្រធានក្រុមការងារមន្ត្រីមានសមត្ថកិច្ច ឱ្យបានយ៉ាងតិច ៤៨ (សែសិបប្រាំបី) ម៉ោង មុនកាលបរិច្ឆេទដែលស្នើសុំកែប្រែនោះ។ រាល់ការជូនដំណឹងត្រូវធ្វើតាមរយៈប្រព័ន្ធទូរស័ព្ទរបស់ប្រធានក្រុមការងារមន្ត្រីមានសមត្ថកិច្ច និងសារអេឡិចត្រូនិករបស់អគ្គនាយកដ្ឋានធនធានរ៉ែអាសយដ្ឋាន gdmr.mme@gmail.com។

ប្រធានក្រុមការងារមន្ត្រីមានសមត្ថកិច្ច ត្រូវឆ្លើយតបចំពោះការជូនដំណឹងអំពីកាលបរិច្ឆេទស្លរ៉ែមាសរបស់សម្បទានិកដែលមានអាជ្ញាបណ្ណយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោង បន្ទាប់ពីទទួលបានការជូនដំណឹងនោះ និងត្រូវចាត់ចែងចូលរួមរាល់ដំណើរការស្លរ៉ែមាសរបស់សម្បទានិកដែលមានអាជ្ញាបណ្ណប្រកបដោយការទទួលខុសត្រូវខ្ពស់។

សម្បទានិកដែលមានអាជ្ញាបណ្ណមិនត្រូវធ្វើការស្លរ៉ែមាស ដោយគ្មានវត្តមានមន្ត្រីមានសមត្ថកិច្ចចូលរួមជាដាច់ខាត លើកលែងតែក្នុងករណីដែលមន្ត្រីមានសមត្ថកិច្ចបានបញ្ជាក់អំពីការចូលរួមដំណើរការស្លរ៉ែមាសរួចហើយ ហើយបែរជាមិនបានចូលរួមក្នុងដំណើរការស្លរ៉ែមាសនេះវិញ នោះសម្បទានិកដែលមានអាជ្ញាបណ្ណមានសិទ្ធិចាត់ចែងដំណើរការស្លរ៉ែមាសតាមកម្មវិធីដែលបានគ្រោងទុក ប៉ុន្តែត្រូវថតជារូបភាពនៃដំណើរការស្លរ៉ែមាសប្រគល់ជូនមន្ត្រីមានសមត្ថកិច្ចវិញ។

## ប្រការ៦.. ភាតព្វកិច្ចសហការរបស់សម្បទានិកដែលមានអាជ្ញាបណ្ណ

សម្បទានិកដែលមានអាជ្ញាបណ្ណ ត្រូវចាត់ចែងអនុវត្តនូវវិធានការចាំបាច់នានា ដើម្បីសម្របសម្រួលជូនដល់មន្ត្រីមានសមត្ថកិច្ច ក្នុងដំណើរការកត់ត្រាទិន្នន័យស្លរ៉ែមាសនៅក្នុងបន្ទប់ស្លរ៉ែមាស ឱ្យប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព។

សម្បទានិកដែលមានអាជ្ញាបណ្ណ ត្រូវចាត់ចែងឱ្យមានសំលៀកបំពាក់ និងឧបករណ៍ផ្នែកសុវត្ថិភាពចាំបាច់នានាជូនមន្ត្រីមានសមត្ថកិច្ច ដើម្បីអនុវត្តការងារឱ្យបានរលូន និងប្រកបដោយសុវត្ថិភាពក្នុងបន្ទប់ស្លរ៉ែមាស។



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

**ប្រការ៧.  ការកំណត់ចំនួនមន្ត្រីមានសមត្ថកិច្ចក្នុងបន្ទប់ស្លរ៉ែមាស**

ក្នុងដំណើរការស្លរ៉ែមាសមួយលើកៗ មន្ត្រីមានសមត្ថកិច្ចអាចចូលរួមយ៉ាងច្រើន ០២ (ពីរ) រូប ប៉ុណ្ណោះ ក្នុងបន្ទប់ស្លរ៉ែមាស ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន។

**ប្រការ៨.  សិទ្ធិ និងការទទួលខុសត្រូវរបស់មន្ត្រីមានសមត្ថកិច្ច**

ក្នុងពេលបំពេញបេសកកម្ម មន្ត្រីមានសមត្ថកិច្ច មានសិទ្ធិដូចខាងក្រោម៖

- អាចចេញ-ចូលនៅក្នុងបន្ទប់ស្លរ៉ែមាស ក្នុងអំឡុងពេលដំណើរការស្លរ៉ែមាសម្តងៗ ដោយមានវត្តមានតំណាងសម្បទានិកដែលមានអាជ្ញាបណ្ណនៅជាមួយ
- កត់ត្រាចំនួន ទម្ងន់ និងអត្តសញ្ញាណដុំមាស (Gold Doré Bar) នីមួយៗដែលផលិតបាន
- កត់ត្រាទម្ងន់សំណាកដុំមាសដែលបានយកចេញពីដុំមាសនីមួយៗ ដើម្បីតាមដានកត់ត្រាគុណភាពនៃសំណាកដុំមាសនីមួយៗនោះ ក្រោយពេលទទួលបានលទ្ធផលវិភាគពីការពិសោធន៍
- វាយត្រាស្ងួតសម្គាល់លើគ្រប់ផលិតផលដុំមាសដែលផលិតបាន។ ត្រាស្ងួតសម្គាល់នេះ នឹងត្រូវកំណត់ដោយប្រកាសរបស់ក្រសួងរ៉ែ និងថាមពល
- ត្រួតពិនិត្យកាមេរ៉ាសុវត្ថិភាពនៅក្នុងករណីមានការសង្ស័យ។ ក្នុងករណីរកឃើញភាពមិនប្រក្រតី មន្ត្រីមានសមត្ថកិច្ចមានសិទ្ធិថតចម្លងឯកសារក្នុងកាមេរ៉ាសុវត្ថិភាពនោះដើម្បីទុកជាភស្តុតាង។ រាល់ការពិនិត្យកាមេរ៉ាសុវត្ថិភាពម្តងៗត្រូវមានកំណត់ហេតុ ដោយចុះហត្ថលេខាទទួលស្គាល់រវាងមន្ត្រីមានសមត្ថកិច្ច និងសម្បទានិកដែលមានអាជ្ញាបណ្ណ
- ធ្វើការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនូវឧបករណ៍រង្វាស់រង្វាល់ ដើម្បីរក្សាបាននូវតម្លាភាព និងសុក្រឹតភាពជាមួយស្ថាប័នមានសមត្ថកិច្ច
- ធ្វើការផ្ទៀងផ្ទាត់ និង/ឬស្នើសុំឱ្យមានការផ្ទៀងផ្ទាត់ទម្ងន់ និងអត្តសញ្ញាណដុំមាស/សំណាកមាសនីមួយៗដែលខ្លួនមានការសង្ស័យ ឬពុំទាន់ទទួលបានព័ត៌មានជាក់ច្បាស់ ក្នុងអំឡុងពេលស្លរ៉ែមាសម្តងៗ
- ផ្អាកដំណើរការស្លរ៉ែមាសជាបណ្តោះអាសន្ន ក្នុងករណីមន្ត្រីមានសមត្ថកិច្ចពិនិត្យឃើញថា បុគ្គលិករបស់សម្បទានិកដែលមានអាជ្ញាបណ្ណពុំព្រមសហការ និង/ឬរារាំងដល់ដំណើរការអង្កេតពិនិត្យជាប្រក្រតីរបស់មន្ត្រីមានសមត្ថកិច្ច។ ក្នុងករណីនេះ មន្ត្រីមានសមត្ថកិច្ចត្រូវរាយការណ៍ជូនថ្នាក់ដឹកនាំជាបន្ទាន់ និងស្នើសុំអនុសាសន៍ណែនាំអនុវត្តបន្ត។

ក្នុងពេលបំពេញបេសកកម្ម មន្ត្រីមានសមត្ថកិច្ច មានការទទួលខុសត្រូវដូចខាងក្រោម៖

- អនុលោមតាមបទដ្ឋាន និងលក្ខខណ្ឌសុវត្ថិភាព ក្នុងការដ្ឋានប្រតិបត្តិការអាជីវកម្មរ៉ែ
- រក្សាការសម្ងាត់វិជ្ជាជីវៈ ដោយរក្សាការសម្ងាត់នូវព័ត៌មាន ឬទិន្នន័យពាក់ព័ន្ធនឹងផលិតផលដុំមាស ឬកន្លែងទុកដាក់ និងប្រតិបត្តិការស្លរ៉ែមាសទាំងមូល
- ទទួលខុសត្រូវចំពោះកំណត់ត្រាទិន្នន័យអំពីចំនួន ទម្ងន់ និងអត្តសញ្ញាណផលិតផលដុំមាស/សំណាកមាស។



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១ ) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥ ) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥ ) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

## ប្រការ៩.. សិទ្ធិ និងការទទួលខុសត្រូវរបស់សម្បទានិកដែលមានអាជ្ញាបណ្ណ

សម្បទានិកដែលមានអាជ្ញាបណ្ណ មានសិទ្ធិដូចខាងក្រោមៈ

- ផ្ទៀងផ្ទាត់លិខិតឧទ្ទេសនាមរបស់មន្ត្រីមានសមត្ថកិច្ច មុននឹងអនុញ្ញាតឱ្យចូលបន្ទប់ស្លរ៉ែមាស
- រាយការណ៍ចំពោះអវត្តមានរបស់មន្ត្រីមានសមត្ថកិច្ច ក្នុងដំណើរការស្លរ៉ែមាសដែលបានគ្រោងទុកជូនក្រសួងរ៉ែនិងថាមពល
- កំណត់អំពីបទដ្ឋាននិងលក្ខខណ្ឌសុវត្ថិភាពសម្រាប់មន្ត្រីមានសមត្ថកិច្ចនៅក្នុងកន្លែងស្លរ៉ែមាស

សម្បទានិកដែលមានអាជ្ញាបណ្ណ មានការទទួលខុសត្រូវដូចខាងក្រោមៈ

- រៀបចំកាលវិភាគ និងកំណត់កាលបរិច្ឆេទនៃដំណើរការស្លរ៉ែមាសដូចមានចែងក្នុងប្រការ៥ នៃប្រកាសនេះ
- គ្រប់គ្រង និងធ្វើប្រតិបត្តិការស្លរ៉ែមាសក្នុងបន្ទប់ស្លរ៉ែមាស
- វាយត្រាលេខអត្តសញ្ញាណសម្គាល់ដុំមាសនីមួយៗ
- ខួងយកសំណាកមាសចំនួន ០២ (ពីរ) សំណាក ពីដុំមាសនីមួយៗ ដើម្បីធ្វើការពិនិត្យពិសោធន៍គុណភាពមាស
- ថ្លឹងផលិតផលដុំមាស និង/ឬសំណាកមាស នីមួយៗដោយកត់ត្រាទិន្នន័យទាំងនោះឱ្យបានត្រឹមត្រូវ
- គ្រប់គ្រងការទុកដាក់ផលិតផលដុំមាស និង/ឬសំណាកមាសឱ្យមានសុវត្ថិភាព
- សម្របសម្រួលជាមួយមន្ត្រីមានសមត្ថកិច្ច និងដោះស្រាយរាល់បញ្ហានានាឱ្យអស់លទ្ធភាព ដើម្បីជំរុញឱ្យដំណើរការកត់ត្រាទិន្នន័យ និងស្លរ៉ែមាសប្រព្រឹត្តទៅបានរលូន
- បំពាក់កាមេរ៉ាសុវត្ថិភាពក្នុងបន្ទប់ស្លរ៉ែមាស ដោយត្រូវរក្សាទុកទិន្នន័យឱ្យបានយ៉ាងតិច ០១ (មួយ) ឆ្នាំ
- កត់ត្រាព័ត៌មាន និងទិន្នន័យផលិតផលដុំមាស និង/ឬសំណាកមាស
- ចាត់ចែង និងបង្កលក្ខណៈល្អប្រសើរចំពោះការអនុវត្តការងាររបស់មន្ត្រីមានសមត្ថកិច្ច
- រក្សាសុវត្ថិភាពរបស់មន្ត្រីមានសមត្ថកិច្ចក្នុងបន្ទប់ស្លរ៉ែមាស និងក្នុងការដ្ឋានប្រតិបត្តិការជនជានរ៉ែរបស់ខ្លួន
- រក្សាការសម្ងាត់អត្តសញ្ញាណរបស់មន្ត្រីមានសមត្ថកិច្ច។

## ប្រការ១០.. កំណត់ត្រា និងរបាយការណ៍អំពីប្រតិបត្តិការស្លរ៉ែមាស

ទម្រង់កំណត់ត្រាស្តីពីទិន្នន័យផលិតផលដុំមាស/សំណាកមាស ត្រូវរៀបចំ និងមានការឯកភាពគ្នារវាងប្រធានក្រុមការងារមន្ត្រីមានសមត្ថកិច្ច និងតំណាងសម្បទានិកដែលមានអាជ្ញាបណ្ណ។

ក្នុងពេលដំណើរការស្លរ៉ែមាសមួយលើកៗ ត្រូវធ្វើកំណត់ត្រាស្តីពីទិន្នន័យផលិតផលដុំមាស/សំណាកមាសឱ្យបានត្រឹមត្រូវចំនួន ០២ (ពីរ) ច្បាប់ ហើយមន្ត្រីមានសមត្ថកិច្ច និងតំណាងសម្បទានិកដែលមាន



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១ ) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥ ) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥ ) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

អាជ្ញាបណ្ណ ត្រូវចុះហត្ថលេខាទទួលស្គាល់លើកំណត់ត្រានេះ។ កំណត់ត្រានេះ ត្រូវរក្សាទុកដោយមន្ត្រីមានសមត្ថកិច្ចចំនួន ០១ (មួយ) ច្បាប់ និងសម្បទានិកដែលមានអាជ្ញាបណ្ណចំនួន ០១ (មួយ) ច្បាប់។

មន្ត្រីមានសមត្ថកិច្ចត្រូវធ្វើកំណត់ហេតុរួមស្តីពីលទ្ធផលក្នុងដំណើរការស្លរ៉ែមាសមួយលើកៗ ដោយមានចុះហត្ថលេខាទទួលស្គាល់រវាងមន្ត្រីមានសមត្ថកិច្ច និងតំណាងសម្បទានិកដែលមានអាជ្ញាបណ្ណ។

ប្រធានក្រុមការងារមន្ត្រីមានសមត្ថកិច្ច ត្រូវរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃដំណើរការស្លរ៉ែមាសរបស់សម្បទានិកកាន់អាជ្ញាបណ្ណ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល។

## ប្រការ១១. ការរក្សាព័ត៌មាន និងទិន្នន័យសម្ងាត់

កំណត់ត្រាដែលត្រូវបានចាត់ទុកជាទិន្នន័យ និងព័ត៌មានសម្ងាត់រួមមាន៖

- កាលបរិច្ឆេទនៃការស្លរ៉ែមាស
- ចំនួនផលិតផលដុំមាស
- ទម្ងន់ដុំមាស
- អត្តសញ្ញាណដុំមាស
- ទីតាំងរក្សាទុកដុំមាស
- អត្តសញ្ញាណដុំមាសដែលបានដឹកជញ្ជូនចេញ
- កាលបរិច្ឆេទនៃការដឹកជញ្ជូនចេញមួយលើកៗ
- អត្តសញ្ញាណរបស់មន្ត្រីមានសមត្ថកិច្ច និងតំណាងសម្បទានិកដែលមានអាជ្ញាបណ្ណដែលបម្រើការងារក្នុងកន្លែងស្លរ៉ែមាស។

មន្ត្រីមានសមត្ថកិច្ចដែលទទួលបានព័ត៌មាន ឬទិន្នន័យសម្ងាត់ខាងលើ អាចប្រើប្រាស់ទិន្នន័យនិងព័ត៌មានសម្ងាត់ទាំងនោះ សម្រាប់តែធ្វើការផ្ទៀងផ្ទាត់ប៉ុណ្ណោះ ប៉ុន្តែមិនអនុញ្ញាតឱ្យមានការថតចម្លង និង/ឬការចែកចាយបន្តទៅឱ្យតតិយជនផ្សេងទៀត ដោយគ្មានការឯកភាពពីសម្បទានិកដែលមានអាជ្ញាបណ្ណឡើយ លើកលែងតែមានការសម្រេចដោយឡែកពីរដ្ឋមន្ត្រី សម្រាប់គោលបំណងអធិការកិច្ច និងផលប្រយោជន៍សាធារណៈផ្នែកសេដ្ឋកិច្ចនិងសង្គម។

## ប្រការ១២. វិធានការចំពោះករណីល្មើសនឹងប្រកាសនេះ

សម្បទានិកដែលមានអាជ្ញាបណ្ណ ដែលល្មើសនឹងបញ្ញត្តិនៃប្រកាសនេះ ឬដែលបង្កការរំខាន ឬរារាំងដោយចេតនាចំពោះការបំពេញការងាររបស់មន្ត្រីមានសមត្ថកិច្ច ត្រូវទទួលទោសស្របតាមច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

មន្ត្រីមានសមត្ថកិច្ច ដែលប្រព្រឹត្តល្មើសនឹងបញ្ញត្តិនៃប្រកាសនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗទៀតជាធរមាន ត្រូវទទួលទណ្ឌកម្ម អនុលោមតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

**ប្រការ១៣.. បទនិនិទកម្ម**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ១៤.. ភារអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានមន្ទីររ៉ែនិងថាមពលរាជធានី-ខេត្ត និងសម្បទានិកដែលមានអាជ្ញាបណ្ណ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ១១កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី-ខេត្ត
- ដូចប្រការ១៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១ ) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥ ) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥ ) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh